ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបតំណាងនិងជានាយកប្រចាំតំបន់នៃអង្គការ
អភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ **UNIDO** ដែលទើបតែងតាំងថ្មី




នៅរសៀលថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Edward Clarence Smith** តំណាងនិងជានាយកប្រចាំតំបន់នៃអង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ UNIDO មានការិយាល័យនៅទីក្រុង បាងកក ប្រទេសថៃ ដែលទើបតែងតាំងថ្មី ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសំដែងការស្វាគមន៍ និងអបអរសាទរចំពោះលោក **Edward Clarence Smith** ដែលត្រូវបានតែងតាំងថ្មី ជាតំណាងនិងជានាយកប្រចាំតំបន់នៃអង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហ

ប្រជាជាតិ UNIDO។ ឯកឧត្តម បានវាយតម្លៃខ្ពស់ចំពោះសកម្មភាពការងាររបស់អង្គការ UNIDO និងបានថ្លែអំណរគុណដល់អង្គការនេះ ដែលបានជួយជ្រោមជ្រែងជាច្រើនដល់ដំណើរការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជា រួមនិងគម្រោងអភិវឌ្ឍន៍វិស័យដ៏ទៃទៀត ដូចជា:វិស័យស្តង់ដារ–មាត្រាសាស្ត្រ–បរិស្ថានឧស្សាហកម្ម–ការអភិវឌ្ឍន៍ឧស្សាហកម្មបៃតង និងផលិតកម្មស្អាត ។ ល។

លោក Edward Clarence Smith តំណាងនិងជានាយកប្រចាំតំបន់នៃអង្គការ UNIDO បានកោតសរសើរចំពោះកិច្ចសហការដ៏ល្អ រវាងកម្ពុជា និងអង្គការ UNIDO ក្នុងការអនុវត្តគម្រោងនានា ក្នុងប្រទេស ។ លោកបានបន្ថែមថា: អង្គការ UNIDO បានត្រៀមខ្លួនជាស្រេច ដើម្បីបន្តសហការការជាមួយកម្ពុជា លើគម្រោងអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ក៏ដូចជា បរិស្ថានឧស្សាហកម្មនិងការបណ្តុះបណ្តាលធនធានមនុស្សជាដើម។ ក្នុងនាមអង្គការ UNIDO លោក **Edward Clarence Smith** ក៏បានវាយតម្លៃខ្ពស់ចំពោះការគាំទ្ររបស់កម្ពុជាលើសេចក្តីព្រាងឯកសារស្តីពីគោលដៅអភិវឌ្ឍន៍ឧស្សាហកម្មប្រកបដោយចិរភាព ដែលជាឯកសារគោលនយោបាយដ៏សំខាន់សម្រាប់ដំណើរការឧស្សាហកម្មពិភពលោក ដោយបានរួមបញ្ចូលនូវការទទួលខុសត្រូវផ្នែកបរិស្ថាន ។

ស្ថិតក្នុងឱកាសនោះ លោក **Edward Clarence Smith** បានផ្តល់សារៈសំខាន់ទៅលើឧស្សាហកម្មកែច្នៃនាំចេញដោយកម្ពុជា ជាប្រទេសកសិកម្ម ហើយលោកក៏ចង់ស្វែងយល់ពីគោលនយោបាយ ក៏ដូចជា គោលដៅអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជាផងដែរ ។



ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា: កម្ពុជាមានសេដ្ឋកិច្ចពឹងផ្អែកលើការនាំចេញ ។ បច្ចុប្បន្នឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងមន្ត្រីជំនាញក្រសួងឧស្សាហកម្ម កំពុងពិនិត្យកែសម្រួលលើសេចក្តីព្រាងឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២៤ ។ ទាក់ទង និងឧស្សាហកម្មកែច្នៃនាំចេញ រាជរដ្ឋាភិបាលកម្ពុជា មានការយកចិត្តទុដាក់ខ្ពស់ គឺដើម្បីកែច្នៃផលិតផលក្នុងស្រុកធ្វើការនាំចេញជាជាងការលក់វត្ថុធាតុដើម ដែលធ្វើឱ្យបាត់បង់តម្លៃបន្ថែម ដូចជាផលិតផលកសិកម្ម និងផលិតផលនេសាទជាដើម ។ តាមរយៈនេះ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស SEZ គឺជាដំណោះស្រាយដ៏សំខាន់ ហើយថ្ងៃអនាគតការបង្កើតយតំបន់សេដ្ឋកិច្ច

ពិសេស ក្រៅពីការវិនិយោគរបស់ឯកជន រដ្ឋក៏អាចធ្វើការវិនិយោគផងដែរ បើមានការសហការជាមួយដៃគូអភិវឌ្ឍន៍ ។ ពីព្រោះថា ក្នុងបរិបទនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន និងការវិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ វិស័យឧស្សាហកម្មពិតជាដើរតួដ៏សំខាន់ ហើយកម្ពុជា ជាចំណុចកណ្ដាលអាស៊ាន ដែលត្រូវមានឧត្តមភាពផ្នែកផលិតកែច្នៃ ដើម្បីផ្គត់ផ្គង់ គាំទ្រ និងការនាំចេញ ។